ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៧៥០ សហវ.ប្រក.ពត

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែមេសាឆ្នាំ ២០០២

# ប្រកាស
## ស្តីពី
## ការបង្កើតប្រព័ន្ធគណនីនៃគណនេយ្យ ថវិកាឃុំ សង្កាត់
## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ន.ស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/រកម/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០១/នស/ ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ ១៩៩៣ដែលប្រកាស អោយប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ហើយមានការកែប្រែក្នុង ច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលត្រូវបានប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១ នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង មានការកែប្រែក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលត្រូវបានប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០១ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០២
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែមិនា ឆ្នាំ ២០០១ដែលប្រកាសអោយប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៥ ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ ៨២អនក្រ/បកចុះថ្ងៃទី ១៦ខែវិច្ឆិកាឆ្នាំ ១៩៩៥ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៤ អ.ន.ក្រ/បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

១០៤

- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ/បកចុះថ្ងៃទី ២៥ ខែកុម្ភៈឆ្នាំ ២០០២ ស្តីពីមូលនិធិ ឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ/បកចុះថ្ងៃទី ០២ ខែមេសា ឆ្នាំ ២០០២ស្តីពីប្រពន្ធ័គ្រប់គ្រងហិរញ្ញវត្ថុ ឃុំ សង្កាត់
- បានឃើញប្រកាសលេខ ០០៩ប្រក.សហវ ចុះថ្ងៃទី ២២ខែ មករា ឆ្នាំ ១៩៩៤ ស្តីពីប្រព័ន្ធគណនីរបស់ធនាគារជាតិ
- តាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**សំរេច**

**ប្រការ ១:** បង្កើតនិងដាក់អោយប្រើនូវប្លង់គណនេយ្យទូទៅមួយសំរាប់កត់ត្រាឆ្លុះបញ្ចាំងការប្រើប្រាស់ថវិកាឃុំ សង្កាត់ ។ លេខសំគាល់ ឈ្មោះគណនី តារាងបែងចែកក្រុមគណនី និង បែបបទទូទៅនៃកិច្ចដំណើរការគណនីត្រូវបាន រៀបចំ ដូចមាននៅក្នុងឧបសម្ព័ន្ធទី១ ឧបសម្ព័នទី២ និង ឧបសម្ព័នទី៣ នៃប្រកាសនេះ ។

**ប្រការ ២:** កិច្ចបញ្ជីការគណនេយ្យរបស់ថវិកាឃុំ សង្កាត់ គឺត្រូវកាន់កាប់ដោយគណនេយ្យកររបស់ធនាគារខេត្ត ក្រុង។

**ប្រការ ៣:** អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធានធនាគារជាតិ និង អង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់តាំងពីថ្ងៃចុះហត្ថលេខាតទៅ ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**គាត ឈន់**

***កន្លែងទទួល***

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
  គណៈកម្មាធិការជាតិគាំទ្រឃុំ-សង្កាត់
- គ្រប់ខេត្ត-ក្រុង
  "ដើម្បីសហការអនុវត្ត"
- ដូចប្រការ ៣
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## តារាងមាតិកាគណនីនៃគណនេយ្យ ឧបសម្ព័ន្ធទី ១

## ទូទៅសំរាប់ថវិកា ឃុំ សង្កាត់

| ល.រ | លេខគណនី | ឈ្មោះគណនី | សមតុល្យ |
|---|---|---|---|
| | | **គណនីថ្នាក់ ១ : គណនីលទ្ធផល មូលនិធិបំរុង** | |
| 1 | 10 | មូលនិធិបំរុង | ឥណទាយី |
| 2 | 12 | លទ្ធផលនៃឆ្នាំថវិកា | ឥណទាយី |
| | | **គណនីថ្នាក់ ៤ : គណនីភតិយជន** | |
| 3 | 40 | ឥណទាយីផ្សេងៗ | ឥណទាយី |
| 4 | 41 | ឥណាយិកផ្សេងៗ | ឥណាយិក |
| 5 | 42 | ប្រាក់តំកល់ធានាបានទទួល | ឥណទាយី |
| | | **គណនីថ្នាក់ ៥ : គណនីរតនវត្ថុ** | |
| 6 | 51 | ប្រាក់បញ្ញើនៅរតនាគារ | ឥណាយិក |
| 7 | 52 | ប្រាក់បញ្ញើនៅធនាគារ | ឥណាយិក |
| 8 | 53 | បេឡានៅឃុំ សង្កាត់ | ឥណាយិក |
| | | **គណនីថ្នាក់ ៦ : គណនីចំណាយ** | |
| 9 | 60 | ចំណាយបៀវត្ស ប្រាក់បំណាច់ | ឥណាយិក |
| 10 | 61 | ចំណាយរដ្ឋបាលទូទៅ | ឥណាយិក |
| 11 | 62 | ចំណាយសេវាសាធារណៈ | ឥណាយិក |
| 12 | 63 | ចំណាយសំរាប់មុខងារជាភ្នាក់ងារ | ឥណាយិក |
| 13 | 64 | ចំណាយអន្តរាគមន៍ផ្នែកសង្គមកិច្ច | ឥណាយិក |
| 14 | 65 | ចំណាយអន្តរាគមន៍ផ្នែកសេដ្ឋកិច្ច | ឥណាយិក |
| 15 | 66 | ចំណាយមិនបានគ្រោងទុក | ឥណាយិក |
| 16 | 67 | ចំណាយវិនិយោគផ្នែករដ្ឋបាលទូទៅ | ឥណាយិក |
| 17 | 68 | ចំណាយវិនិយោគអភិវឌ្ឍន៍មូលដ្ឋាន | ឥណាយិក |
| | | **គណនីថ្នាក់ ៧ : គណនីចំណូល** | |
| 18 | 70 | ចំណូលពន្ធមូលដ្ឋាន | ឥណទាយី |
| 19 | 71 | ចំណូលមិនមែនសារពើពន្ធ-សេវា-ទ្រព្យសម្បត្តិ | ឥណទាយី |
| 20 | 72 | ចំណូលពីមូលនិធិ ឃុំ សង្កាត់ សំរាប់ដំណើរការរដ្ឋបាលទូទៅ | ឥណទាយី |
| 21 | 73 | ចំណូលពីការអនុវត្តន៍មុខងារជាភ្នាក់ងារ | ឥណទាយី |
| 22 | 74 | ចំណូលចរន្តផ្សេងៗ | ឥណទាយី |
| 23 | 76 | ចំណូលពីមូលនិធិបំរុង | ឥណទាយី |
| 24 | 77 | ចំណូលពីមូលនិធិ ឃុំ សង្កាត់ សំរាប់អភិវឌ្ឍន៍មូលដ្ឋាន | ឥណទាយី |
| 25 | 78 | ចំណូលពីការរួមចំណែករបស់ប្រជាពលរដ្ឋមូលដ្ឋាន | ឥណទាយី |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឧបសម្ព័ន្ធទី ២

# តារាងបែងចែកក្រុមគណនីនៃគណនេយ្យទូទៅសំរាប់ថវិកា ឃុំ-សង្កាត់

| ល.រ | លេខគណនី | ឈ្មោះគណនី | សមតុល្យ |
|---|---|---|---|
| | | ១- ក្រុមគណនីតុល្យភាព : (គណនីស្ថានការណ៍) | |
| 1 | 10 | មូលនិធិបំរុង | ឥណទាយី |
| 2 | 12 | លទ្ធផលនៃឆ្នាំថវិកា | ឥណទាយី |
| 3 | 40 | ឥណទាយីផ្សេងៗ | ឥណទាយី |
| 4 | 41 | ឥណាយិកផ្សេងៗ | ឥណាយិក |
| 5 | 42 | ប្រាក់តំកល់ធានាបានទទួល | ឥណទាយី |
| 6 | 51 | ប្រាកបញ្ញើនៅរតនាគារ | ឥណាយិក |
| 7 | 52 | ប្រាក់បញ្ញើនៅធនាគារ | ឥណាយិក |
| 8 | 53 | បេឡានៅឃុំ សង្កាត់ | ឥណាយិក |
| | | ២- ក្រុមគណនីគ្រប់គ្រង ( គណនីចំណូល-ចំណាយ ) | |
| | | ក- ក្រុមគណនីចំណាយ | |
| | | + ចំណាយចរន្ត | ឥណាយិក |
| 9 | 60 | ចំណាយបៀវត្ស ប្រាក់បំណាច់ | ឥណាយិក |
| 10 | 61 | ចំណាយរដ្ឋបាលទូទៅ | ឥណាយិក |
| 11 | 62 | ចំណាយសេវាសាធារណៈ | ឥណាយិក |
| 12 | 63 | ចំណាយសំរាប់មុខងារជាភ្នាក់ងារ | ឥណាយិក |
| 13 | 64 | ចំណាយអន្តរាគមន៍ផ្នែកសង្គមកិច្ច | ឥណាយិក |
| 14 | 65 | ចំណាយអន្តរាគមន៍ផ្នែកសេដ្ឋកិច្ច | ឥណាយិក |
| 15 | 66 | ចំណាយមិនបានគ្រោងទុក | ឥណាយិក |
| | | + ចំណាយមូលធន | |
| 17 | 67 | ចំណាយវិនិយោគផ្នែករដ្ឋបាលទូទៅ | ឥណាយិក |
| 18 | 68 | ចំណាយវិនិយោគអភិវឌ្ឍន៍មូលដ្ឋាន | ឥណាយិក |
| | | ខ. ក្រុមគណនីចំណូល | |
| | | + ចំណូលចរន្ត | |
| 19 | 70 | ចំណូលពន្ធមូលដ្ឋាន | ឥណទាយី |
| 20 | 71 | ចំណូលមិនមែនសារពើពន្ធ- សេវា- ទ្រព្យសម្បត្តិ | ឥណទាយី |
| 21 | 72 | ចំណូលពីមូលនិធិ ឃុំ សង្កាត់ សំរាប់ដំណើរការរដ្ឋបាលទូទៅ | ឥណទាយី |
| 22 | 73 | ចំណូលពីការអនុវត្តន៍មុខងារជាភ្នាក់ងារ | ឥណទាយី |
| 23 | 74 | ចំណូលចរន្តផ្សេងៗ | ឥណទាយី |
| | | + ចំណូលជាមូលធន | |
| 24 | 76 | ចំណូលពីមូលនិធិបំរុង | ឥណទាយី |
| 25 | 77 | ចំណូលពីមូលនិធិ ឃុំ សង្កាត់ សំរាប់អភិវឌ្ឍន៍មូលដ្ឋាន | ឥណទាយី |
| 26 | 78 | ចំណូលពីការរួមចំណែករបស់ប្រជាពលរដ្ឋមូលដ្ឋាន | ឥណទាយី |
| 27 | 79 | ចំណូលជាមូលធនផ្សេងៗ | ឥណទាយី |

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

************

**ប្រព្រឹត្តិកម្មរបស់គណនីនៃគណនេយ្យ** ឧបសម្ពន្ធទី ៣

**ទូទៅសំរាប់ថវិកា ឃុំ សង្កាត់**

---

## ១. <u>គណនីមូលនិធិបំរុង “ 10 ”</u>

គណនីនេះប្រើសំរាប់កត់ត្រាមូលនិធិបំរុងរបស់ឃុំ សង្កាត់ ពុំទាន់បានចាត់ចែង ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនមូលនិធិបំរុងរបស់ឃុំសង្កាត់ដែលបានផ្ទេរទៅជាចំណូលថវិកា របស់ឆ្នាំក្រោយ

ឥណទាន : កត់ត្រាលទ្ធផលនៃឆ្នាំថវិកាដែលបានផ្ទេរមកជាមូលនិធិបំរុងរបស់ឃុំ សង្កាត់

សមតុល្យឥណទាយី : បង្ហាញអំពីមូលនិធិបំរុងរបស់ ឃុំសង្កាត់ ដែលពុំទាន់បានចាត់ចែង ។

## ២. <u>គណនីលទ្ធផលនៃឆ្នាំថវិកា “ 12 ”</u>

គណនីនេះប្រើសំរាប់ប្រមូលផ្តុំសមតុល្យនៃគណនីចំណូល និង គណនីចំណាយដើម្បីគណនារកលទ្ធផលនៅចុងឆ្នាំថវិកា ។ ជាគោលការណ៍គណនីនេះមានតែសមតុល្យឥណទាយី ឬ អសមតុល្យ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនសមតុល្យនៃគណនីចំណាយដែលបានផ្ទេរមក
កត់ត្រាលទ្ធផលនៃឆ្នាំថវិកាដែលបានផ្ទេរទៅគណនីមូលនិធិបំរុង

ឥណទាន : កត់ត្រាចំនួនសមតុល្យនៃគណនីចំណូលដែលបានផ្ទេរមក

សមតុល្យឥណទាយី : បង្ហាញអំពីលទ្ធផលអតិរេក ដែលសំរេចបានក្នុងឆ្នាំថវិកាហើយពុំទាន់ បានចាត់ចែង ។

## ៣. <u>គណនីឥណទាយីផ្សេងៗ “ 40 ”</u>

គណនីនេះមានលក្ខណៈបំរុង សំរាប់ប្រតិបត្តិការចំលងនានាដែលមិនអាចចាំន់ស្ពានបាន ។ ជាគណនី រង់ចាំ ឬ បំណុល

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាខ្ទង់ទឹកប្រាក់បានសង

ឥណទាន : កត់ត្រាខ្ទង់ទឹកប្រាក់ត្រូវសង

សមតុល្យឥណទាយី : បង្ហាញអំពីចំនួនទឹកប្រាក់ត្រូវសងពុំទាន់បានដោះស្រាយ ។

## ៤. <u>គណនីឥណាយិកផ្សេងៗ “ 41 ”</u>

គណនីនេះប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ដែលផ្តល់ជាបុរេប្រទាន ជូន អ្នកផ្គត់ផ្គង់ អ្នកម៉ៅការ...ជាប្រាក់កក់បានបង់ ឬ ខ្ទង់ត្រូវទារផ្សេងៗ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលឃុំ សង្កាត់ បានផ្តល់ជាបុរេប្រទានដល់អ្នកផ្គត់ផ្គង់ អាជីវករ ជាប្រាក់កក់ បានបង់

ឬ ខ្ទង់ត្រូវទារ ក្នុងករណីចាំបាច់ ដែលពុំអាចចេញអាណត្តិបើកប្រាក់បាន

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ដែលអ្នកផ្គត់ផ្គង់ អាជីវករ អ្នកម៉ៅការ បានទូទាត់វិញជាសាច់ប្រាក់ ឬបង្វែរ ឬ ជាអាណត្តិ បើកប្រាក់

សមតុល្យឥណាយិក : បង្ហាញអំពីចំនួនប្រាក់បុរេប្រទាន ឬប្រាក់កក់មុនពុំទាន់បានទូទាត់ ។ ជាគោលការណ៍គណនីនេះត្រូវអសមតុល្យនៅដំណាច់ឆ្នាំ ។

៥. **គណនីប្រាក់តំកល់ធានាបានទទួល " 42 "**

គណនីនេះប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់កក់ធានាដែល ឃុំ សង្កាត់ បានទទួលពីអាជីវករ សហគ្រិន អ្នកម៉ៅការ អ្នកផ្គត់ផ្គង់ ក្រោមរូបភាពសាច់ប្រាក់ ឬ បង្វែរ ។

ការកត់ត្រា :

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ ដែលអាជីវករបានបង់ជូនឃុំ សង្កាត់ ក្រោមរូបភាព សាច់ប្រាក់ ឬ បង្វែរ

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលឃុំ សង្កាត់ បានសងទៅអាជីវករ អ្នកម៉ៅការ អ្នកផ្គត់ផ្គង់ក្រោមរូបភាព សាច់ប្រាក់ ឬបង្វែរ

កត់ត្រាចំនួនទឹកប្រាក់ដែលអាជីវក អ្នកម៉ៅការ អ្នកផ្គត់ផ្គង់ បានបង្វែរចូលគណនីចំណូលរបស់ឃុំ សង្កាត់

សមតុល្យឥណទាយី : បង្ហាញអំពីចំនួនទឹកប្រាក់កក់ធានា ដែលឃុំ សង្កាត់ បានទទួល ហើយពុំទាន់បានចាត់ចែង ។

៦. **គណនីប្រាក់បញ្ញើនៅរតនាគារ " 51 "**

គណនីនេះប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់បញ្ញើដែលឃុំ សង្កាត់បានទទួល និងបានដក ។គណនី នេះឆ្លុះបញ្ចាំងត្រឡប់ ជាមួយ គណនីប្រាក់បញ្ញើរបស់ ឃុំ សង្កាត់ " 425 " នៅក្នុងគណនេយ្យថវិការដ្ឋ

ការកត់ត្រា :

ឥណពន្ធ : ការកត់ត្រាចំនួនទឹកប្រាក់ដែល ឃុំ សង្កាត់ បានទទួលក្រោមរូបភាពសាច់ប្រាក់ ឬ បង្វែរ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ដែល ឃុំ សង្កាត់ បានដកចេញក្រោមរូបភាពសាច់ប្រាក់ ឬ បង្វែរ (សំរាប់ចំណាយ កក់ធានា ឬ ផ្តល់បុរេប្រទាន... )

សមតុល្យឥណាយិក : បង្ហាញអំពីចំនួនប្រាក់បញ្ញើរបស់ ឃុំ សង្កាត់ កំពុងមាននៅរតនាគារ ។

៧. **គណនីប្រាក់បញ្ញើនៅធនាគារ " 52 "**

គណនីនេះប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់បញ្ញើដែលឃុំ សង្កាត់ បានផ្ញើនៅធនាគារពាណិជ្ជណាមួយ យោងតាមការសំរេចយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលឃុំ សង្កាត់ បានទទួលក្រោមរូបភាពសាច់ប្រាក់ ឬបង្វែរ ដែលផ្ញើនៅធនាគារ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ដែល ឃុំ សង្កាត់ បានដកចេញពីធនាគារក្រោមរូបភាពសាច់ប្រាក់ ឬ បង្វែរ

សមតុល្យឥណាយិក : បង្ហាញអំពីចំនួនប្រាក់បញ្ញើរបស់ ឃុំ សង្កាត់កំពុងមាននៅធនាគារ ។

**៨. គណនីបេឡាសៅ ឃុំ សង្កាត់ "53"**

គណនីនេះប្រើសំរាប់កត់ត្រាចំនួនសាច់ប្រាក់បេឡាដែលឃុំ សង្កាត់ បានផ្តល់ ( បុរេប្រទាន ) ដល់ មន្ត្រីគ្រប់គ្រងបេឡា បុរេប្រទាន ក្នុងគោលដៅបំរើអោយការចំណាយរដ្ឋបាល ក្នុងករណីមិនអាចចេញអាណត្តិបើកប្រាក់បានទាន់ពេលវេលាសំរាប់ ចំណាយ ដែលមានទឹកប្រាក់តិច...និង ក្នុងករណីដែលមិនអាចទូទាត់ត្រង់ទៅអ្នកផ្គត់ផ្គង់បាន ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលមន្ត្រីគ្រប់គ្រងបេឡាបុរេប្រទានរបស់ឃុំ សង្កាត់ បានទទួលជាសាច់ប្រាក់ទុកសំរាប់ចំណាយ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ដែលមន្ត្រីគ្រប់គ្រងបេឡាបុរេប្រទានរបស់ ឃុំ សង្កាត់ បានទូទាត់ជាអាណត្តិបើកប្រាក់ ឬ ជាសាច់ប្រាក់

សមតុល្យឥណទេយិក : បង្ហាញអំពីចំនួនសាច់ប្រាក់ដែលមន្ត្រីគ្រប់គ្រងបេឡាបុរេប្រទាន ឃុំ សង្កាត់ កំពុងកាន់កាប់ ។

**៩ គណនីចំណាយបៀវត្ស ប្រាក់បំណាច់ "60"**

គណនីនេះប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក ចំណាយលើបៀវត្ស ប្រាក់បំណាច់ កំរៃផ្សេងៗ របស់ក្រុមប្រឹក្សា ឃុំ សង្កាត់ បុគ្គលិក អ្នកជំនាញនានា ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណាយបៀវត្ស ប្រាក់បំណាច់ កំរៃ របស់បុគ្គលិក ក្រុមប្រឹក្សា ឃុំ សង្កាត់

ឥណទាន : កត់ត្រាផ្ទេរសមតុល្យនៅចុងឆ្នាំថវិកាចូលទៅគណនីលទ្ធផល

កត់ត្រាបន្ថយចំណាយ ឬ និយ័ត្តកម្ម

សមតុល្យឥណពេយិក : បង្ហាញអំពីចំនួនប្រាក់ចំណាយលើបៀវត្ស ប្រាក់បំណាច់ កំរៃផ្សេងៗដែលពុំទាន់ផ្ទេរចូលគណនីលទ្ធផល ។

**៩ គណនីចំណាយរដ្ឋបាលទូទៅ "61"**

គណនីនេះប្រើសំរាប់កត់ត្រាទឹកប្រាក់ចំណាយ សំរាប់បំរើការអោយការងាររដ្ឋបាល ដូចជា ចំណាយ ថ្លៃឈ្នួលទីតាំង ការជួសជុល ថែទាំ ទឹក អគ្គីសនី ធ្វើដំណើរ ប្រេងឥន្ធនៈ ទូរគមនាគមន៍ ( ទូរស័ព្ទ ប្រៃសណីយ ) សំភារៈការិយាល័យ ប្រជុំ ពិធីបុណ្យ ឯកសារ ពត៌មាន សេវាលើការផ្ទេរប្រាក់ និង ចំណាយផ្សេងៗទៀត... ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណាយរដ្ឋបាល ដោយសាច់ប្រាក់ ឬ បង្វែរ

ឥណទាន : កត់ត្រាផ្ទេរសមតុល្យនៅចុងឆ្នាំថវិកា ចូលទៅគណនីលទ្ធផល

កត់ត្រាបន្ថយចំណាយ ឬ និយ័ត្តកម្ម

សមតុល្យឥណពេយិក : បង្ហាញអំពីចំនួនទឹកប្រាក់ចំណាយរដ្ឋបាលដែលពុំទាន់បានផ្ទេរ ចូលគណនីលទ្ធផល

**១១. គណនីចំណាយសេវាសាធារណៈ "62"**

គណនីនេះប្រើសំរាប់កត់ត្រាចំណាយលើសេវាទាក់ទងនឹង ហេដ្ឋារចនាសម្ព័ន្ធ ទ្រព្យសម្បត្តិសាធារណៈ ដូចជា ការថែទាំ ជួសជុល ប្រព័ន្ធទឹក ប្រឡាយ ព្រែក ស្ពាន អគារសាធារណៈ មធ្យោបាយបំរើការសាធារណៈ អគ្គីសនី ទឹក សួនច្បារសធារណ

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណាយ សេវាសាធារណៈដោយសាច់ប្រាក់ ឬ បង្វែរ

ឥណទាន : កត់ត្រាផ្ទេរសមតុល្យចុងឆ្នាំថវិកា ចូលទៅគណនីលទ្ធផល

កត់ត្រាបន្ថយចំណាយ ឬ និយ័ត្តកម្ម

សមតុល្យឥណាយិក : បង្ហាញអំពីចំនួនទឹកប្រាក់ ចំណាយសេវាសាធារណៈដែលពុំទាន់បានផ្ទេរ ចូលគណនីលទ្ធផល ។

១២_ **គណនីចំណាយសំរាប់មុខងារជាភ្នាក់ងារ " 63 "**

គណនីនេះប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ ចំណាយទាក់ទងដល់ការបំពេញមុខងារ ជាភ្នាក់ងាររបស់រដ្ឋ របស់អង្គការ ស្ថាប័ននានា លើការងារផ្តល់សេវា ឬ វិនិយោគ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណាយ សំរាប់ការបំពេញមុខងារជាភ្នាក់ងារជាសាច់ប្រាក់ ឬ ជាបង្វែរ

ឥណទាន : កត់ត្រាផ្ទេរសមតុល្យនៅចុងឆ្នាំថវិកា ចូលទៅគណនីលទ្ធផល

កត់ត្រាបន្ថយចំណាយ ឬ និយ័ត្តកម្ម

សមតុល្យឥណាយិក : បង្ហាញអំពីចំនួនទឹកប្រាក់ចំណាយសំរាប់មុខងារជាភ្នាក់ងារដែលពុំទាន់បានផ្ទេរ ចូលគណនីលទ្ធផល ។

១៣_ **គណនីចំណាយអន្តរាគមន៍ផ្នែកសង្គមកិច្ច " 64 "**

គណនីនេះប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយលើការឧបត្ថម្ភ ទ្រទ្រង់ ទាក់ទងដល់វិស័យសង្គមកិច្ច ដូចជា ជំនួយ អំណោយ សំរាប់ជនរងគ្រោះ ស្ត្រីមេម៉ាយ ជរា កុមារកំព្រា ស្លាប់ មានជំងឺ ឆេះផ្ទះ ទឹកជំនន់ គ្រោះថ្នាក់ ជួយសមាគម ជួយវត្តអារាម ឃុំ ស្រុក ខេត្ត ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណាយ អន្តរាគមន៍នានា លើផ្នែកសង្គមកិច្ច ដោយ សាច់ប្រាក់ ឬ បង្វែរ

ឥណទាន : កត់ត្រាផ្ទេរសមតុល្យនៅចុងឆ្នាំថវិកា ចូលទៅគណនីលទ្ធផល

កត់ត្រាបន្ថយចំណាយ ឬ និយ័ត្តកម្ម

សមតុល្យឥណាយិក : បង្ហាញអំពីចំនួនទឹកប្រាក់ចំណាយអន្តរាគមន៍ផ្នែកសង្គមកិច្ចដែលពុំទាន់បានផ្ទេរ ចូលគណនីលទ្ធផល ។

១៤_ **គណនីចំណាយអន្តរាគមន៍ផ្នែកសេដ្ឋកិច្ច " 65 "**

គណនីនេះប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ ចំណាយលើការឧបត្ថម្ភដល់វិស័យសេដ្ឋកិច្ច ដូចជា ជំនួយ អំណោយ សំរាប់ការរាំងស្ងួត ស្រូវពូជ ថ្នាំសំលាប់សត្វល្អិត ជីគីមី ទ្រទ្រង់ថ្លៃ .... ។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណាយ អន្តរាគមន៍នានា លើផ្នែកសេដ្ឋកិច្ច ដោយ សាច់ប្រាក់ ឬ បង្វែរ

ឥណទាន : កត់ត្រាផ្ទេរសមតុល្យនៅចុងឆ្នាំថវិកា ចូលទៅគណនីលទ្ធផល

កត់ត្រាបន្ថយចំណាយ ឬ និយ័ត្តកម្ម

សមតុល្យឥណាយិក : បង្ហាញអំពីចំនួនទឹកប្រាក់ចំណាយអន្តរាគមន៍ផ្នែកសេដ្ឋកិច្ចដែលពុំទាន់បានផ្ទេរ ចូលគណនីលទ្ធផល ។

## ១៥. គណនីចំណាយមិនបានគ្រោងទុក " 66 "

គណនីនេះ ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ ចំណាយនានាដែលមិនបានគ្រោងទុកក្រោយពីមានការឯកភាពពី ក្រុមប្រឹក្សា ឃុំ សង្កាត់ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណាយ មិនបានគ្រោងទុក ដោយ សាច់ប្រាក់ ឬ បង្វែរ

ឥណទាន : កត់ត្រាផ្ទេរសមតុល្យនៅចុងឆ្នាំថវិកា ចូលទៅគណនីលទ្ធផល

កត់ត្រាបន្ថយចំណាយ ឬ និយ័ត្តកម្ម

សមតុល្យឥណាយិក : បង្ហាញអំពីចំនួនទឹកប្រាក់ចំណាយមិនបានគ្រោងទុក ដែលពុំទាន់បានផ្ទេរ ចូលគណនីលទ្ធផល ។

## ១៦. គណនីចំណាយវិនិយោគផ្នែករដ្ឋបាលទូទៅ " 67 "

គណនីនេះប្រើសំរាប់កត់ត្រាចំណាយបំរើអោយការវិនិយោគលើផ្នែករដ្ឋបាល ដូចជាទិញ ឬ សាងសង់អគារការិយាល័យ ទិញសំភារៈ ឧបករណ៍ សង្ហារឹមការិយាល័យ មធ្យោបាយធ្វើដំណើរ បំរើអោយការងាររដ្ឋបាល ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណាយវិនិយោគផ្នែករដ្ឋបាលទូទៅ ក្រោមរូបភាព សាច់ប្រាក់ ឬ បង្វែរ

ឥណទាន : កត់ត្រាផ្ទេរសមតុល្យនៅចុងឆ្នាំថវិកា ចូលគណនីលទ្ធផល

កត់ត្រាបន្ថយចំណាយ ឬ និយ័ត្តកម្ម

សមតុល្យឥណាយិក : បង្ហាញអំពីចំនួនទឹកប្រាក់ចំណាយវិនិយោគផ្នែករដ្ឋបាលទូទៅពុំទាន់បានផ្ទេរ ចូលគណនីលទ្ធផល ។

## ១៧. គណនីចំណាយវិនិយោគអភិវឌ្ឍន៍មូលដ្ឋាន " 68 "

គណនីនេះប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយលើ ការវិនិយោគអភិវឌ្ឍន៍មូលដ្ឋាន ដូចជា សំណង់ ហេដ្ឋារចនាសម្ព័ន្ធ មន្ទីរពេទ្យ សាលារៀន ប្រព័ន្ធទឹកស្អាត...ជាដើម ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ ចំណាយ សំរាប់វិនិយោគអភិវឌ្ឍន៍មូលដ្ឋានដោយ សាច់ប្រាក់ ឬ បង្វែរ

ឥណទាន : កត់ត្រាផ្ទេរសមតុល្យនៅចុងឆ្នាំថវិកា ចូលគណនីលទ្ធផល

កត់ត្រាបន្ថយចំណាយ ឬ និយ័ត្តកម្ម

សមតុល្យឥណាយិក : បង្ហាញអំពីចំនួនទឹកប្រាក់ ចំណាយវិនិយោគអភិវឌ្ឍន៍មូលដ្ឋាន ពុំទាន់បានផ្ទេរ ចូលគណនីលទ្ធផល ។

## ១៨. គណនីចំណូលពន្ធមូលដ្ឋាន " 70 "

គណនីនេះប្រើសំរាប់កត់ត្រាចំណូលរបស់ ឃុំ សង្កាត់ ដែលបានមកពីពន្ធមូលដ្ឋាន ក្រោមរូបភាព បង់ជាសាច់ប្រាក់ ឬ បង្វែរ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាផ្ទេរសមតុល្យនៅចុងឆ្នាំថវិកា ចូលគណនីលទ្ធផល

កត់ត្រាបន្ថយចំណូល ឬ និយ័ត្តកម្ម

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានពីពន្ធមូលដ្ឋានក្រោមរូបភាពជា សាច់ប្រាក់ ឬ បង្វែរ

សមតុល្យឥណទាយី : បង្ហាញអំពីចំនួនទឹកប្រាក់ ចំណូលពីពន្ធមូលដ្ឋាន ដែលពុំទាន់បានផ្ទេរ ចូលគណនីលទ្ធផល ។

**១៩_ គណនីចំណូលមិនមែនសារពើពន្ធ_សេវា_ទ្រព្យសម្បត្តិ " 71 "**

គណនីនេះ ប្រើសំរាប់កត់ត្រាចំណូលដែលបានមកពីប្រភពមូលដ្ឋាន ដូចជា ការផ្តល់សេវា រដ្ឋបាល អនាម័យ ទឹកស្អាត ការប្រើប្រាស់ទឹកផលិតកម្ម ការប្រើ ផ្លូវ ស្ពាន ស្រះ អណ្តូងទឹករួម ឈ្នួលទីតាំង និង ការប្រើប្រាស់លើទ្រព្យសម្បត្តិផ្សេងៗ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាផ្ទេរសមតុល្យនៅចុងឆ្នាំថវិកា ចូលគណនីលទ្ធផល

កត់ត្រាបន្ថយចំណូល ឬ និយ័ត្តកម្ម

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលក្រោមរូបភាពជា សាច់ប្រាក់ ឬ បង្វែរ

សមតុល្យឥណទាយី : បង្ហាញអំពីចំនួនទឹកប្រាក់ចំណូលដែលពុំទាន់បានផ្ទេរ ចូលគណនីលទ្ធផល ។

**២០_ គណនីចំណូលពីមូលនិធិ ឃុំ សង្កាត់ សំរាប់ដំណើរការរដ្ឋបាលទូទៅ " 72 "**

គណនីនេះប្រើសំរាប់កត់ត្រាចំណូលដែលបានមកពី វិភាជន៍ ផ្ទេរពីមូលនិធិ ឃុំ សង្កាត់ សំរាប់ចំណាយដំណើរការរដ្ឋបាល ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាផ្ទេរសមតុល្យនៅចុងឆ្នាំថវិកា ចូលគណនីលទ្ធផល

កត់ត្រាបន្ថយចំណូល ឬ និយ័ត្តកម្ម

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានមកពីការផ្ទេរពីមូលនិធិឃុំ សង្កាត់ទុកសំរាប់ចំណាយរដ្ឋបាល

សមតុល្យឥណទាយី : បង្ហាញអំពីទឹកប្រាក់ចំណូល ពីមូលនិធិ ឃុំ សង្កាត់ដែលពុំទាន់បានផ្ទេរចូលគណនីលទ្ធផល។

**២១_ គណនីចំណូលពីការអនុវត្តន៍មុខងារជាភ្នាក់ងារ " 73 "**

គណនីនេះប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ដែលបានមកពីការផ្តល់ធនធានពីក្រសួង មន្ទីរ អង្គការ សមាគម សំរាប់បំរើអោយការចំណាយលើមុខងារជាភ្នាក់ងារ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាផ្ទេរសមតុល្យនៅចុងឆ្នាំថវិកា ចូលគណនីលទ្ធផល

កត់ត្រាបន្ថយចំណូល ឬ និយ័ត្តកម្ម

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានមកពីការផ្តល់ធនធានពី ក្រសួងមន្ទីរ អង្គការ សមាគម ក្រោមរូបភាពជា សាច់ប្រាក់ ឬ បង្វែរ

សមតុល្យឥណទាយី : បង្ហាញអំពីចំនួនទឹកប្រាក់ចំណូលពីមុខងារជាភ្នាក់ងារដែលពុំទាន់បាន ផ្ទេរចូលគណនីលទ្ធផល ។

**២២_ គណនីចំណូលចរន្តផ្សេងៗ " 74 "**

គណនីនេះប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ដែលបានមកពីប្រភពផ្សេងទៀត ក្រៅពីប្រភពខាងលើ ទុកសំរាប់បំរើអោយចំណាយចរន្ត។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាផ្ទេរសមតុល្យនៅចុងឆ្នាំថវិកា ចូលគណនីលទ្ធផល

កត់ត្រាបន្ថយចំណូល ឬ និយ័ត្តកម្ម

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូល ដែលបានពីប្រភពផ្សេងទៀត ក្រោមរូបភាពជា សាច់ប្រាក់ ឬ បង្វែរ

សមតុល្យឥណទាយី : បង្ហាញអំពីចំនួនទឹកប្រាក់ចំណូលចរន្តផ្សេងៗពុំទាន់បាន ផ្ទេរចូលគណនីលទ្ធផល ។

២៣. **គណនីចំណូលពីមូលនិធិបំរុង "76"**

គណនីនេះប្រើសំរាប់កត់ត្រាចំណូលដែលបានមកពីផ្ទេរពីមូលនិធិបំរុងរបស់ឆ្នាំមុន ។ ចំណូលពីមូលនិធិបំរុងគឺទុកសំរាប់តែបំរើអោយការចំណាយវិនិយោគ តែប៉ុណ្ណោះ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាផ្ទេរសមតុល្យនៅចុងឆ្នាំថវិកា ចូលគណនីលទ្ធផល

កត់ត្រាបន្ថយចំណូល ឬ និយ័ត្តកម្ម

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូល ដែលបានមកពីការផ្ទេរពីមូលនិធិបំរុងទុកសំរាប់ចំណាយវិនិយោគ ។

សមតុល្យឥណទាយី : បង្ហាញអំពីចំនួនទឹកប្រាក់ចំណូលពីមូលនិធិបំរុងពុំទាន់បានផ្ទេរចូលគណនីលទ្ធផល

២៤. **គណនីចំណូលពីមូលនិធិ ឃុំ សង្កាត់ សំរាប់អភិវឌ្ឍន៍មូលដ្ឋាន "77"**

គណនីនេះប្រើសំរាប់កត់ត្រាចំណូល ដែលបានមកពីវិភាជន៍ ពីមូលនិធិ ឃុំ សង្កាត់ ទុកសំរាប់ចំណាយ អភិវឌ្ឍន៍ មូលដ្ឋាន ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាផ្ទេរសមតុល្យនៅចុងចុងឆ្នាំថវិកា ចូលគណនីលទ្ធផល

កត់ត្រាបន្ថយចំណូល ឬ និយ័ត្តកម្ម

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូល ដែលបានមកពីការផ្ទេរពីមូលនិធិ ឃុំ សង្កាត់ ទុកសំរាប់ចំណាយវិនិយោគមូលដ្ឋាន ។

សមតុល្យឥណទាយី : បង្ហាញអំពីចំនួនទឹកប្រាក់ចំណូលទុកសំរាប់អភិវឌ្ឍន៍មូលដ្ឋានពុំទាន់បានផ្ទេរ ចូលគណនីលទ្ធផល

២៥. **គណនីចំណូលពីការរួមចំណែករបស់ប្រជាពលរដ្ឋមូលដ្ឋាន "78"**

គណនីនេះប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ដែលបានមកពីការចូលរួមចំណែករបស់ប្រជាពលរដ្ឋ លើគំរោងវិនិយោគរបស់ ឃុំ សង្កាត់ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាផ្ទេរសមតុល្យនៅចុងឆ្នាំថវិកា ចូលគណនីលទ្ធផល

កត់ត្រាបន្ថយចំណូល ឬ និយ័ត្តកម្ម

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូល ដែលប្រជាពលរដ្ឋបានបង់ក្រោមរូបភាពជា សាច់ប្រាក់ ឬ បង្វែរ

សមតុល្យឥណទាយី : បង្ហាញអំពីចំនួនទឹកប្រាក់ចំណូល ដែលបានមកពីប្រជាពលរដ្ឋ ហើយពុំទាន់បានផ្ទេរ ចូលគណនីលទ្ធផល ។

## ២៦. គណនីចំណូលជាមូលធនផ្សេងៗ “ 79 ”

គណនីនេះប្រើសំរាប់កត់ត្រាទឹកប្រាក់ចំណូលបានមកពីសប្បុរសជន អង្គការជាតិ អង្គការអន្តរជាតិ ការលក់ទ្រព្យសម្បត្តិដែលឃុំសង្កាត់ គ្រប់គ្រង អំណោយ និង ពីប្រភពផ្សេងៗទៀតដែលផ្តល់ទៅ ឃុំ សង្កាត់ ក្នុងគោលដៅអភិវឌ្ឍន៍ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាផ្ទេរសមតុល្យនៅចុងឆ្នាំថវិកា ចូលគណនីលទ្ធផល

កត់ត្រាបន្ថយចំណូល ឬ និយ័ត្តកម្ម

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលជាមូលធនផ្សេងៗដែលបានទទួលក្រោមរូបភាពជាសាច់ប្រាក់ ឬ បង្វែរ

សមតុល្យឥណទាយី : បង្ហាញអំពីចំនួនទឹកប្រាក់ចំណូលជាមូលធនផ្សេងៗពុំទាន់បានផ្ទេរ ចូលគណនីលទ្ធផល ។

[illegible]ាត់ : គណនីទាំងឡាយខាងលើអាចបង្កើតជា គណនីរងបន្ថែម សំរាប់តាមដានកត់ត្រាលំអិត ទៅតាមតំរូវការ ជាក់ស្តែងនៃប្រតិបត្តិការ ។